# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**
**និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
**លេខ:០០៥/០៧ របក.អគគ**

## របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ មករា ឆ្នាំ ២០០៧របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែ មករា ឆ្នាំ ២០០៧ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមាន អង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិ បត្តិ បានដំណើរការងាររបស់ ខ្លួនស្របតាម បេសកកម្ម ដែល បានកំណត់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេច បាននូវលទ្ធផល ជាក់ស្តែង ដូចខាងក្រោម ៖

**១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិ**

ក. <u>ការងាររដ្ឋបាល</u>

- ផ្ញើដីកាអមរបាយការណ៍ស្តីពីការទស្សនាតុលាការខេត្តកណ្តាល កាលពីថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៦
- ទទួលរបាយការណ៍ស្តីពីការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ សម្រាប់ឆ្នាំ ២០០៦ ពី ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ទទួលកម្រងសាលក្រមតុលាការកំពូល បញ្ជូនទៅបោះពុម្ពនៅអគ្គនាយកដ្ឋានរាជកិច្ច
- ទទួលលិខិតពីវិទ្យាស្ថានគ្រប់គ្រងបូព៌ា-បស្ចឹម EWMI ស្នើសុំការគាំទ្រ ពីក្រុមប្រឹក្សា កំណែទម្រង់ ច្បាប់ និងប្រព័ន្ធយុត្តិធមិ CLJR ទៅក្រសួងការបរទេស និងសហ-ប្រតិបត្តិការ អន្តរជាតិ ពន្យារ កិច្ចសហប្រតិបត្តិការ
- ទំនាក់ទំនង និងត្រៀមក្រុមប្រតិបត្តិគម្រោង PEG/A2J

ខ. <u>ការងារកំណែទម្រង់</u>

-រៀបចំរបាយការណ៍ប្រចាំឆ្នាំ ២០០៦ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធមិ

- រៀបចំចងក្រង Project Profile

-ជួយពិនិត្យរបាយការណ៍បញ្ចប់ស្តីពីការស្ទង់មតិអំពីជំនួយផ្នែកច្បាប់ ជាភាសាអង់គ្លេស

-ជួបពិភាក្សាជាមួយគណៈមេធាវីកម្ពុជា លើរបាយការណ៍នៃការស្ទង់មតិ អំពីជំនួយផ្នែកច្បាប់ នៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧

-ប្រជុំជាមួយតំណាង UNDP រៀបចំបែងចែកថវិកាចំណាយសម្រាប់គម្រោង សិទ្ធិទទួលបានយុត្តិធម៌ នៅកម្ពុជា ឆ្នាំ ២០០៧ នៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៧

-ប្រជុំជាមួយនឹងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ UNDP ត្រៀមរៀបចំ សិក្ខាសាលាស្តីពីការ បង្កើតប្រព័ន្ធទិន្នន័យ អំពីកម្មវិធីលើកកំពស់ការ យល់ដឹងសិទ្ធិមនុស្សនៅមូលដ្ឋាន លើគម្រោង A2J លេខ ១.១.១

-រៀបចំ និងបញ្ជូនឯកសារស្តីពីលក្ខណៈវិនិច្ឆ័យថ្នាក់ជាតិសម្រាប់តុលាការគំរូកម្ពុជា ទៅជូនអ្នក គ្រប់គ្រងគម្រោង (ភរៀញចេត Manager) នៃ DIHR ។

-ធ្វើការពិភាក្សាជាមួយតំណាង DIHR លោក Anders Buhelt និង Ben Vase ដើម្បីតាក់តែង Project Document និង Cooperation Agreement រវាង PCB/PMU និង DIHR សម្រាប់ឆ្នាំ ២០០៧ ។

គ. ផ្សេងៗ

-ចូលរួមរៀបចំវេទិកាសម្រាប់ព្រឹទ្ធសភា និងរដ្ឋសភា ស្តីពីកំណែទម្រង់រដ្ឋរបស់រាជរដ្ឋាភិបាល ក្រោម អធិបតីភាពឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារ អាំងទែរកុងទីណង់តាល់ នៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៧

**២-សន្និដ្ឋាន**

ក្នុងខែ មករា ឆ្នាំ ២០០៦ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាព គ្រប់គ្រងគម្រោងជាអង្គភាព ប្រតិបត្តិ បានខិតខំបំពេញការងារយ៉ាង សកម្មក្នុងការរៀបចំមូលដ្ឋាន សម្រាប់ការអនុវត្តកំណែទម្រង់ច្បាប់ និងតុលាការ ជាពិសេសលើការងាររៀបចំបញ្ចប់បញ្ជីគម្រោង សម្រាប់ចែកជូនអង្គការ ក្រសួងស្ថាប័នពាក់ព័ន្ធពិនិត្យ ធ្វើសមទិន និងការជម្រុញការអនុវត្តកម្មវិធី សិទ្ធិទទួលបានយុត្តិធម៌ នៅកម្ពុជា A2Jដោយកិច្ចសហការពីអង្គការ UNDP ។

**៣-ទិសដៅអនុវត្តក្នុងខែបន្ត**

- បន្តការងារបញ្ចប់ការរៀបចំ Project Profile
- បន្តការជម្រុញការអនុវត្តកម្មវិធី A2J (RGC/UNDP)

- បន្តការផ្លាស់ប្តូរយោបល់ ដើម្បីបញ្ចប់ Project Document

-តាមដានភាពជឿនលឿននៃការអនុវត្តកម្មវិធីសកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្រ្ត កំណែទម្រង់ ច្បាប់ និងតុលាការ ។

*រាជធានី ភ្នំពេញ ថ្ងៃទី ខែ កុម្ភៈ ឆ្នាំ ២០០៧*

**អ្នកធ្វើរបាយការណ៍**

**ហ៊្សង សុកុល**

**បានឃើញ និងឯកភាព**

**នាយកអង្គភាពគ្រប់គ្រងគម្រោង**

**ស៊ុយ ម៉ុងលាង**